ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសំរួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១:** ត្រូវបានកែសំរួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ទៅជា គណៈកម្មាធិការជាតិ សម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ។

**ប្រការ ២:** គណៈកម្មាធិការជាតិ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ប្រាក់ សុខុន | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តម ម៉ឹង សំផន | រដ្ឋលេខាធិការ ក្រសួងការពារជាតិ | អនុប្រធាន |
| ៣- ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

៤- ឯកឧត្តម ឌិត អ៊ីម៉ុន រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៥- ឯកឧត្តម ណឹម សុខន្តិ ទីប្រឹក្សា និងជានាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ទៀ បាញ់ សមាជិកអចិន្ត្រៃយ៍

៦- ឯកឧត្តម សុខ ផេង អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល សមាជិក

៧- ឯកឧត្តម ជា តារា នាយរងសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ សមាជិក

៨- ឯកឧត្តម សំ ចណ្ណថន អគ្គលេខាធិការ ក្រសួងការពារជាតិ សមាជិក

៩- ឯកឧត្តម ស៊ុំ សំណាង អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ ក្រសួងការពារជាតិ សមាជិក

១០- ឯកឧត្តម ចៅ តិរុណ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈ-បច្ចេកទេស ក្រសួងការពារជាតិ សមាជិក

១១- ឯកឧត្តម មាស សាវ៉ន អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ សមាជិក

១២- ឯកឧត្តម ខ្វាន់ ស៊ីម មេបញ្ជាការ កងវិស្វកម្ម អគ្គបញ្ជាការ សមាជិក

១៣- ឯកឧត្តម មាស សំរុល នាយកនាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ សមាជិក

១៤- ឯកឧត្តម សែម សុចណ្ណនី អគ្គលេខាធិការរង អាជ្ញាធរមីន សមាជិក

១៥- តំណាង ក្រសួងមហាផ្ទៃ សមាជិក

១៦- តំណាង ក្រសួងសាធារណៈការ និងដឹកជញ្ជូន សមាជិក

**ប្រការ ៣:** គណៈកម្មាធិការជាតិ មានបេសកកម្ម តួនាទី និងភារកិច្ច ដូចខាងក្រោម :

- សំរបសំរួលកិច្ចការទាំងឡាយ ដែលពាក់ព័ន្ធនឹងការត្រៀមរៀបចំកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ជាមួយក្រសួង ស្ថាប័នផ្សេងៗ ។
- ទំនាក់ទំនងជាមួយ អ.ស.ប ក្នុងការរៀបចំឯកសារ លិខិតបទដ្ឋាននានា សំរាប់បញ្ជូនចូលរួមបំពេញបេសកកម្មរបស់ អ.ស.ប រួមមាន កំលាំងបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នាយទាហានសង្កេតការណ៍ បុគ្គលិកធ្វើការក្នុងក្របខ័ណ្ឌ អ.ស.ប និងការងារ ផ្សេងៗទៀត តាមតំរូវការរបស់ អ.ស.ប និងតាមលទ្ធភាពរបស់កម្ពុជា ។
- លើកយោបល់ និងសំណើផ្ទាល់ជូនរាជរដ្ឋាភិបាលជ្រាប ពិនិត្យ និងសំរេចលើរាល់កិច្ចការពាក់ព័ន្ធនឹងការត្រៀមរៀបចំកំលាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាព អ.ស.ប ។
- លើកគំរោងថវិកាសំរាប់បំពាក់ឧបករណ៍នានា និងបំរើការងារហ្វឹកហ្វឺន ជូនកងកំលាំងគ្រប់ប្រភេទ ដែលនឹងចូលរួមបេសកកម្មរបស់ អ.ស.ប ។

- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន សហគមន៍អ្នកផ្តល់ជំនួយ អង្គការជាតិ និងអន្តរជាតិ ដើម្បីស្វែងរកជំនួយគាំទ្រ ។
- បូកសរុបរបាយការណ៍សកម្មភាពការងារ និងលទ្ធផល ជូនរាជរដ្ឋាភិបាល ។
- អនុវត្តកិច្ចការមួយចំនួនទៀត តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ។

**ប្រការ ៤:** គណៈកម្មាធិការជាតិ មានកញ្ចប់ថវិកាសំរាប់ដំណើរការក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៥:** គណៈកម្មាធិការជាតិ សហការជាមួយក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទដើម្បីបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលផ្នែកប្រតិបត្តិការរក្សាសន្តិភាព អ.ស.ប ។

**ប្រការ ៦:** គណៈកម្មាធិការជាតិ មានទីតាំងនៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៧:** គណៈកម្មាធិការជាតិ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៨:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងសាមីខ្លួនក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ